# រោគក្អកមាន់
**(Pertussis or Whooping Cough)**

វដ្ដវត្រជាក់ច្រើននាំមកនូវបញ្ហាសុខភាពជាច្រើនដល់មនុស្សយើង តាំងពីក្មេងតូចៗ ដល់អស់លោកចាស់ទុំ។ បញ្ហាសុខភាពទាំងនេះមានដូចជា គ្រុនក្ដៅ គ្រុនផ្ដាសាយធម្មតា, គ្រុនផ្ដាសាយធំ, ក្អក, រលាកទងសួត, ហើមសួត ឬក្អកមាន់ជាដើម។

រោគក្អកមាន់ដែលពាក្យអង់គ្លេសហៅថា Whooping Cough ឬ Pertussis ជារោគក្អកម្យ៉ាងដែលឆ្លង យ៉ាងខ្លាំងដោយសារមេរោគបាក់តេរី។ រោគនេះ ច្រើនកើតមានជាមធ្យម ចំពោះក្មេងជំទង់និងមនុស្សពេញវ័យ តែចំពោះក្មេងតូចៗវិញ វាអាចមានលក្ខណៈយ៉ាងធ្ងន់ធ្ងរ។

រោគក្អកមាន់អាចមានរយៈពេលបីវគ្គ។ <u>វគ្គទីមួយ</u> គឺកើតឡើងដោយធ្វើឲ្យអ្នកជម្ងឺគ្រុនផ្ដាសាយ, ហៀរសំបោរ, កណ្ដាស់, និងក្អក។ ការក្អកនេះអាចមានរយៈពេលប្រហែលជាពី មួយអាទិត្យទៅពីរអាទិត្យ បន្ទាប់មក វាធ្វើឲ្យអ្នកជម្ងឺមានលក្ខណៈកាន់តែដុនដាបឡើង។ <u>វគ្គទីពីរ</u> គឺធ្វើឲ្យអ្នកជម្ងឺ ក្អកយ៉ាងខ្លាំងរហូតដល់ពុំអាចទប់ទល់បាន។ បន្ទាប់មក មានធ្វើឲ្យក្អួត ហើយធ្វើឲ្យអ្នកជម្ងឺអ្នកដកដង្ហើមម្ដងៗ ឮសូរសម្លេងដង្ហក់យ៉ាងខ្លាំង។ នៅពេលក្អកខ្លាំងម្ដងៗ វាអាចធ្វើឲ្យស្ទះដង្ហើម ដែលជាហេតុបណ្ដាលឲ្យមុខអ្នកជម្ងឺឡើងពណ៌ស្វាយស្លាំង ពីព្រោះដោយសារ ពុំមានខ្យល់ឧកស៊ីហ្សែនសំរាប់ដកដង្ហើមឲ្យបានគ្រប់គ្រាន់។ នៅពេល ឈប់ក្អកម្ដងៗ អ្នកជម្ងឺនោះមើលទៅដូចមនុស្សជាធម្មតា។ រយៈពេលនេះ គឺអាចមាន ប្រហែលជាពី 2 អាទិត្យ ទៅ 6 អាទិត្យ។ <u>វគ្គទីបី</u> គឺនៅពេលដែលអាការៈទាំងប៉ុន្មានដែល ខ្ញុំបាទបានអធិប្បាយនេះចាប់ចុះអន់ថយបន្តិចទៅ វិញ។ ក្នុងលក្ខណៈនេះ អ្នកជម្ងឺប្រហែលជាអាចនៅមានក្អក ដង្ហក់ម្ដងៗ តែចាប់ផ្ដើមមានសភាពគ្រាន់បើជាងមុន។ ជាទូទៅ ក្អកមាន់ច្រើនមានរយៈពេលពី 6 អាទិត្យ ទៅ 10 អាទិត្យ។

ចំពោះមនុស្សពេញវ័យ, ក្មេងជំទង់, ឬក្មេងតូចៗ ដែលបាន ចាក់ថ្នាំការពាររោគនេះ រួចហើយ ច្រើនមានរោគសញ្ញាជាមធ្យម គឺមាន សញ្ញាដូចជាកើតរោគរលាកទងសួត (Bronchitis) ឬរោគក្អកធម្មតា។

មេរោគដែលបណ្ដាលឲ្យកើតរោគក្អកមាន់ច្រើនមាននៅក្នុងច្រមុះ, មាត់, និងបំពង់ក។ នៅពេលដែលអ្នកជម្ងឺនោះចាប់ កណ្ដាស់, ក្អក, ឬហារមាត់និយាយ មេរោគទាំងនោះអាចហើរចេញទៅតាមខ្យល់អាកាស។ អ្នកដែលនៅជិតខាងនោះ អាចដកដង្ហើមនាំយក មេរោគទាំងនោះចូល

ទៅក្នុងស្បូតជាមួយផង។ ម្យ៉ាងទៀតការប៉ះក្រដាស់ Kleenex ជូតសំបោររបស់អ្នកជម្ងឺ ឬ ប្រើកែវទឹកជាមួយអ្នកជម្ងឺ ក៏អាចធ្វើឲ្យឆ្លងមេរោគក្អកមាន់នេះបានដែរ។ សញ្ញាឬអាការៈរោគមុនដំបូងបង្អស់ ដែលអាចឲ្យយើងដឹងថា អ្នកជម្ងឺឆ្លងរោគ គឺក្នុងរយៈពេលពី 7 ទៅ 10 ថ្ងៃ បន្ទាប់ពីពេលដែលអ្នកជម្ងឺប៉ះពាល់នឹងមេរោគក្អកមាន់។ អ្នកជម្ងឺអាចចម្លងរោគទៅអ្នកដទៃបានក្នុងរយៈពី 2 អាទិត្យ មុនពេលដែលខ្លួនចាប់ផ្តើមក្អកជាដំបូង និង 3 អាទិត្យបន្ទាប់ពីចាប់ ក្អកហើយ ឬរហូតដល់ពេលណា ដែលអ្នកនោះចាប់លេបថ្នាំផ្សះ (Antibiotic) បានចំនួន 5 ថ្ងៃ។

នៅក្នុងរដ្ឋម៉ាស្សាឈូតសេត រោគក្អកមាន់ច្រើនមាន ចំពោះមនុស្សដែលមានអាយុ ពីអាយុ 10 –20 ឆ្នាំ គឺ ជារយៈពេលអស់ជាតិថ្នាំការពាររោគ ដែលខ្លួនបានចាក់កាលនៅពីតូច។ បន្ទាប់មកគឺទារកតូចៗ ពីព្រោះទារកទាំងនោះ នៅតូចពេកថ្នាំបង្ការរោគពុំទាន់មានប្រសិទ្ធភាពការពារ។ ប្រសិនបើនិយាយឲ្យចំទៅ នរណាក៏អាចកើតរោគនេះបានដែរ ហើយវាអាចធ្វើឲ្យពិបាកចាប់ភ្លឹកណាស់ ពីព្រោះអាការៈរោគនេះ មានលក្ខណៈ ប្រហាក់ប្រហែលគ្នា ទៅនឹងអាការៈរោគគ្រុនផ្តាសាយធម្មតា ហើយមានក្អក មិនឈប់ឈរអស់រយៈពេលរាប់អាទិត្យ ឬរាប់ខែ។

រោគក្អកមាន់អាចធ្វើឲ្យមានបញ្ហាពិបាកដកដង្ហើម, ហើមស្បូត, និងហើមស្រោមខួរក្បាល ហើយអាចបណ្តាលឲ្យកើតរោគស្កន់ប្រកាច់ ឬខូចខួរក្បាល។ រោគនេះអាច បណ្តាលឲ្យអ្នកជម្ងឺស្លាប់បាត់បង់ជីវិតបាន ជាពិសេសចំពោះទារកតូចៗ ប៉ុន្តែវាកម្រមានណាស់។ ចំពោះក្មេងធំៗ, ក្មេងជំទង់, និងមនុស្សពេញវ័យវិញ រោគនេះអាចមានលក្ខណៈស្រាលជាមធ្យម តែវាអាចធ្វើឲ្យអ្នកជម្ងឺឈឺ អស់រយៈពេលរាប់អាទិត្យ ឬរាប់ខែ។

វេជ្ជបណ្ឌិតអាចប៉ាន់ស្មានបានថា អ្នកជម្ងឺកើតរោគក្អកមាន់ដោយសារ សញ្ញានៃរោគនេះ។ ប៉ុន្តែម្យ៉ាងទៀត មានតែការយកមេរោគ ឬឈាមទៅធ្វើតែស៍មើលទេ ទើបអាចដឹងពិតប្រាកដបាន។ វិធីយកមេរោគទៅពិនិត្យមើល គឺដោយសារការយកសំឡីកៀកក្នុងច្រមុះ។ ឯការយកឈាមទៅមើលវិញ គឺអាចធ្វើទៅបាន នៅពេលណាដែលអ្នកជម្ងឺនោះឈឺបាន ក្នុងរយៈពេលពីរឬបីអាទិត្យមកហើយ។

មធ្យោបាយសំខាន់ក្នុងការព្យាបាលរោគក្អកមាន់ គឺការសំរាក និងការទទួលទានទឹកឲ្យបានគ្រប់គ្រាន់។ រីឯខ្យល់ឧកស៊ីហ្សែន, ថ្នាំពេទ្យវិញក៏អាចជួយឲ្យអ្នកជម្ងឺអាចដកដង្ហើមបានស្រួលដែរ។ ហើយថ្នាំសណ្តំ (Sedative) វិញ អាចជួយឲ្យអ្នកជម្ងឺសំរាន្តបានស្រួល ដោយកុំឲ្យស្ទូវក្អកពេក។ ថ្នាំផ្សះអាចជួយបង្ក្រាបកុំឲ្យរោគមានកម្លាំងខ្លាំងខ្លា ហើយកុំឲ្យអ្នកជម្ងឺចម្លងមេរោគ ទៅអ្នកដទៃផង។ អ្នកដែលប៉ះពាល់ជាមួយអ្នកជម្ងឺក្អកមាន់ គួរអញ្ជើញទៅឲ្យគ្រូពេទ្យ ចេញសំបុត្រ

ទិញថ្នាំផ្សេះ សំរាប់លេបការពាររោគ ទោះបីជាអ្នកនោះធ្លាប់ចាក់ថ្នាំការពារមកពីមុនមកហើយក៏ដោយ។

ក្មេងដែលមានអាយុតិចជាង 7 ឆ្នាំគួរទៅចាក់ថ្នាំការពារជម្ងឺ DTaP (Diphtheria, tetanus, acellular Pertussis) លើងលែងតែក្មេងនោះមាន ជម្ងឺអ្វីមួយដែលពុំអាចចាក់ថ្នាំនេះបាន។ មុនពេលចាក់ថ្នាំនេះឲ្យ គ្រូពេទ្យនឹងសាកសួរ ថាតើកូន លោកអ្នកធ្លាប់មានរោគស្កន់, ជម្ងឺខួរក្បាលផ្សេងៗ, ឬមានផលវិបត្តិបន្ទាប់ពីចាក់ថ្នាំ DTaP ពីមុនមកដែរឬទេ។ បើសិនជាគ្មានទេ លោកអ្នកគួរ យកកូនទៅចាក់ថ្នាក់ការពារជម្ងឺនេះ នៅពេល កូនមានអាយុ: 2 ខែ, 4 ខែ, 6 ខែ, ពី12 –15 ខែ និងពី 4 – 6 ឆ្នាំ។

ចំពោះពត៌មានបន្ថែមស្តីអំពីរោគក្អកមាន់ លោកអ្នកអាចសាកសួរ គ្រូពេទ្យប្រចាំគ្រួសារ, ក្រសួងសុខាភិបាលនៅតាមតំបន់លោកអ្នក ឬទូរស័ព្ទទៅក្រសួងសាធារណៈសុខាភិបាល នៃរដ្ឋម៉ាស្សាឈូសេត កម្មវិធីចាក់ថ្នាំបង្ការរោគ ទូរស័ព្ទលេខ (617) 983-6800។ ប្រសិនបើ អស់លោក-លោកស្រី ពុំទាន់មានគ្រូពេទ្យប្រចាំគ្រួសារទេនោះ អស់លោក-លោកស្រីអាចអញ្ជើញទូរស័ព្ទទៅ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលដែលមានទូរស័ព្ទលេខ (978) 441-1700 ដើម្បីធ្វើការណាត់ជួប ជ្រើសរើសរកគ្រូពេទ្យប្រចាំគ្រួសាររបស់អស់លោក-លោកស្រី។

*ពត៌មានទាំងនេះដកស្រង់និងបកប្រែចេញអំពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូតសេត ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*